# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 828

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : គម្រោងអភិវឌ្ឍន៍ផែស្ងួត (ICD) កំពង់ផែស្វយ័តក្រុងព្រះសីហនុ

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 03/01/22 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 03/01/24 |
| ៣. ចំណាយគម្រោងសរុប | $39,229,275 |
| ៤. ស្ថាប័នទទួលខុសត្រូវ | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| RESPONSIBLE UNIT | Sihanoukville Autonomous Port |
| អង្គភាពទទួលខុសត្រូវ | កំពង់ផែស្វយ័តក្រុងព្រះសីហនុ |
| ៥. ស្ថានភាពគម្រោង | គម្រោងដែលបានលុបចោល |

ព័ត៌មានលម្អិតអំពីគម្រោង

| | |
|---|---|
| ៦. ប្រភេទគម្រោង ៖ | គម្រោងវិនិយោគជាទុន |
| ៧. ប្រភពហិរញ្ញប្បទាន៖ | ស្វែងរកម្ចាស់ជំនួយ |

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី៤- ការពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធស្បៀង

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

នាពេលបច្ចុប្បន្ន បរិមាណកុងតេន័រឆ្លងកាត់ ក.ស.ស មានប្រមាណ 541,288/ឆ្នាំ (ឆ្នាំ2018) ។ ទន្ទឹមហ្នឹងនេះ ទីលានកុងតេន័រមានស្រាប់មានទំហំ ១៥ ហ.ត ហើយតម្រូវការទីលានទំហំដល់ ៣០ ហ.ត នៅឆ្នាំ២០២៥ខាងមុខ (យោងតាមការសិក្សាតម្រូវការអនាគតរបស់ JICA និង ក.ស.ស) ។ ហេតុដូច្នេះ កសស បានទិញដីទំហំ ប្រមាណ ៥៤ហ.ត ដែលស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៤ ចំងាយប្រមាណ ២៥គ.ម បម្រុងទុកសម្រាប់ធ្វើជា Inland Container Depot (ICD) ។ ក្នុងដំណាក់កាលទី១ ក.ស.ស គ្រោងផែនការរៀបចំអភិវឌ្ឍន៍ដីប្រមាណ ៣០ហ.ត និងបំពាក់គ្រឿងចក្រធុនធ្ងន់សម្រាប់ប្រតិបត្តិការលើកដាក់កុងតេន័រ ។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

ការដឹកជញ្ជូន

**១២. ទីតាំងអនុវត្តគម្រោង** (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

ព្រះសីហនុ,

**១៣. គោលបំណងរបស់គម្រោង** (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

គោលបំណងនៃគម្រោងនេះគឺ ការអភិវឌ្ឍន៍ទីលានស្តុកកុងតេន័រ(ICD) ទំហំ២០ហ.ត និងបំពាក់គ្រឿងចក្រលើកដាក់ កុងតែន័រ ដើម្បីជួយបង្កើនសមត្ថភាពលើកដាក់កុងតេន័ររបស់ ក.ស.ស កាត់បន្ថយការស្ទះចរាចរនៅមុខចំណតផែ កុងតែន័រ បង្កើនប្រសិទ្ធិភាពនៃការប្រើប្រាស់គ្រឿងចក្រ ជា Pre-gate សម្រាប់ ក.ស.ស ជាទីលានស្តុកកុងតែន័រ សំបក (Empty) ជាចំណតរថយន្តកុងតែន័រ និងរថយន្តផ្សេងៗ និងប្រែក្លាយតំបន់ជុំវិញជាតំបន់អភិវឌ្ឍន៍នាអនាគត សម្រាប់ខេត្តព្រះសីហនុ ដោយចូលរួមចំណែកបង្កើនល្បឿនក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចនៃ ព្រះរាជាណាចក្រកម្ពុជា ។

**១៤. ការពិពណ៌នាអំពីគម្រោង** (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

-ការអភិវឌ្ឍន៍ និងសាងសង់ទីលានស្តុកកុងតេន័រ (ICD) ទំហំ ២០ហ.ត
-ការងារលទ្ធកម្មគ្រឿងចក្រលើកដាក់កុងតែន័រ
-ការងារសាងសង់អាគាររដ្ឋបាល រោងជាងជួសជុលថែទាំ និង
-ការងារសេវាទីប្រឹក្សា ។ល។

**១៥. យុត្តិកម្មលើគម្រោង** (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

ការអភិវឌ្ឍន៍ទីលានស្តុកកុងតេន័រ (ICD) ទំហំ ៥៤ហ.ត និងបំពាក់គ្រឿងចក្រលើកដាក់កុងតែន័រ ដើម្បីជួយបង្កើន សមត្ថភាពលើកដាក់កុងតេន័ររបស់ ក.ស.ស កាត់បន្ថយការស្ទះចរាចរនៅមុខចំណតផែកុងតែន័ររៀងរាល់ចុងសប្តាហ៍ បង្កើនប្រសិទ្ធិភាពនៃការប្រើប្រាស់គ្រឿងចក្រកុងតេន័រ ដើម្បីធានាបាននូវនិរន្តរភាព នៃលំហូរទំនិញចេញ-ចូលកំពង់ផែ ប្រកបដោយលក្ខណៈប្រកួតប្រជែងគុណភាពសេវា និងមិនកកស្ទះចរាចរទំនិញនាពេលអនាគត ឆ្លើយតបបាននូវ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ នោះ ។

**១៦. ផលប្រយោជន៍របស់គម្រោង** (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

គម្រោងនេះ នឹងផ្តល់ប្រយោជន៍ដោយផ្ទាល់ដល់ប្រជាពលរដ្ឋខេត្តព្រះសីហនុប្រមាណ ២៣០,០០០នាក់ ហើយ ប្រជាពលរដ្ឋកម្ពុជាប្រមាណ ១៥លាននាក់ នឹងទទួលផលប្រយោជន៍មិនផ្ទាល់ពីគម្រោងនេះ ។

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | មាន |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | ត្រូវបានរៀបចំ |

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

របាយការណ៍វាយតម្លៃផលប៉ះពាល់ផ្នែកបរិស្ថាន ត្រូវបានរៀបចំឡើងក្នុងអំឡុងពេល នៃការសិក្សាលទ្ធភាព ដោយផ្អែក តាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន ។

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **មាន**

ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស **ការបន្សាំ**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការត្រៀម**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**គម្រោងនេះ មិនមានផលប៉ះពាល់ដល់តួនាទីរបស់បុរស និងស្ត្រីក្នុងទីតាំងគម្រោង ក៏ដូចជាការចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះទេ ជាពិសេស ស្ត្រីត្រូវបានលើកទឹកចិត្តក្នុងការបម្រើការងារឱ្យក្រុមហ៊ុនទីប្រឹក្សាគម្រោង ក្រុមហ៊ុនម៉ៅការសាងសង់ និងក្រុមហ៊ុនម៉ៅការបន្តផងដែរ ក្នុងអំឡុងអនុវត្តន៍គម្រោង ។ ក្នុងដំណាក់ប្រតិបត្តិការ គម្រោងនេះនឹងបង្កើតការងារជូនប្រជាពលរដ្ឋក្នុងមូលដ្ឋានរាប់ម៉ឺននាក់ ។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**អង្គភាពគ្រប់គ្រងគម្រោង (PMU) ដែលជាអង្គភាពជំនាញ និងធ្លាប់មានបទពិសោធន៍គ្រប់គ្រាន់សម្រាប់ការអនុវត្តន៍គម្រោងនានាជាមួយដៃគូអភិវឌ្ឍន៍ នឹងត្រូវបានបន្តចាត់ចែង និងអនុវត្តគម្រោងនេះ ។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**គម្រោងបានកំពុងស្វែងរកដៃគូអភិវឌ្ឍន៍ ។**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

**ក្នុងដំណាក់កាលសិក្សាលទ្ធភាព ក.ស.ស រំពឹងទុកថា ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន-Japan International Cooperation Agency (JICA)នឹងបន្តគាំទ្រ និងផ្តល់ប្រាក់កម្ចីសម្បទាន ។**

# ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2021 | | 2022 | 2023 | 2024 | 2025 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2023-2025 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 2,230.0 | 8,393.0 | 14,305.0 | 24,928.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 1,980.0 | 5,955.0 | 5,955.0 | 13,890.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 250.0 | 750.0 | 750.0 | 1,750.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 1,688.0 | 7,600.0 | 9,288.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 2,230.0 | 8,393.0 | 14,305.0 | 24,928.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2021 | | 2022 | 2023 | 2024 | 2025 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2023-2025 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | 0.0 | 0.0 | 0.0 | 2,230.0 | 8,393.0 | 14,305.0 | 24,928.0 | |
| | | | | | | | | |
| Japanse International Cooperation Agency | 0.0 | 0.0 | 0.0 | 2,230.0 | 8,393.0 | 14,305.0 | 24,928.0 | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 0.0 | 0.0 | 0.0 | 2,230.0 | 8,393.0 | 14,305.0 | 24,928.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: